ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# នាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២០១
ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១
សាលដីកា
លេខ: ៣១
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤
ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជី
លោកស្រី [redacted]

តំណាងមហាអយ្យការ
ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៥ក្រIII"ច" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២០១ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ របស់តុលាការកំពូល។

<u>ពីបទ:</u> **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនជាប់ចោទឈ្មោះ[redacted](ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ ទីលំនៅកំណើត ភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃ ភូមិតាម៉ៅកណ្តាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឪពុកឈ្មោះ[redacted]" ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ[redacted]មានកូន៧នាក់ ទោសពីមុនគ្មាន។

ចាប់ខ្លួនថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៧, ឃុំខ្លួនថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧។

-មេធាវីលោក[redacted]



Scanned by CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] ណាក់ ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិតាម៉ៅកណ្តាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្តឹងសាទុក្ខ)

-កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧ ឈ្មោ[redacted]ងឈ្មោ[redacted]ដែលត្រូវជាឪពុកចុងបានទៅធ្វើកម្មករដាំកូនឈើឱ្យក្រុមហ៊ុនចិន នៅឃុំអូរគ្រៀង ក៏បានដេករួមរ័ក្ស និងគ្នាជាញឹកញាប់ច្រើនលើកមកហើយ លុះដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៧ ជនជាប់ចោទឈ្មោ[redacted] បានមកហៅជនរងគ្រោះឈ្មោះឈ្មោ[redacted]ឱ្យទៅដេកជាមួយ តែជនរងគ្រោះមិនព្រមទៅក៏ប្តឹងសមត្ថកិច្ចឱ្យចាប់ខ្លួនតែម្តង។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ ថាៈចោទប្រកាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិតាម៉ៅកណ្តាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ពីបទៈ[redacted]សាពសន្ថវៈដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៦២"ក" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចៈ

១-សម្រេចឱ្យឈ្មោះ[redacted]ភេទប្រុស អាយុ៣៧ឆ្នាំ រួចខ្លួនពីបទចោទប្រកាន់ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៧ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងបង្គាប់ឱ្យដោះលែងឈ្មោះនេះ ចេញពីមន្ទីរឃុំឃាំង ជាបន្ទាន់ភ្លាម ប្រសិនបើឈ្មោះនេះមិនត្រូវជាប់ឃុំ ពីបទល្មើសផ្សេងទៀតទេ។

២-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]ងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៨ របស់លោក[redacted] ព្រះរាជអាជ្ញារង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៦២"ខ" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ បើពិនិត្យទៅលើចម្លើយជនជាប់ចោទ, សាក្សី និងជនរងគ្រោះ មានការប្រែប្រួលចម្លើយនៅព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំ ឱ្យក្រុមប្រឹក្សាពិចារណា តាមមាត្រា២៧ កថាខណ្ឌទី៤ នៃក្រមព្រហ្មទណ្ឌ តែលោកព្រះរាជអាជ្ញា[redacted]ដែលឡើងមកធ្វើសេចក្តីសន្និដ្ឋាន នៅពេលសវនាការ យល់ឃើញ

ជាឪពុកពិតជាបានប្រព្រឹត្តបទល្មើសចាប់រំលោភលើកូនមែន សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសទៅតាមច្បាប់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៥ក្រIII"ច" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ១២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ របស់លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តក្រចេះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ៦២"ក" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តក្រចេះ ចោលជាអសារបង់។

៣-ផ្តន្ទាទោសលើឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិតាម៉ៅកណ្តាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០៧នាក់ ទោសពីមុនគ្មាន ដាក់ពន្ធនាគារកំណត់១០ (ដប់ឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ ពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

៤-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] តាមច្បាប់។

៥-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងជនរងគ្រោះ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១១៨ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៥ក្រIII"ច" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាក្នុងបណ្តឹងសាទុក្ខចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ឯកសារនិងភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងនេះ មានធាតុផ្សំគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទខាងលើពិតជាបានរួមគ្នា ប្រព្រឹត្តបទរំលោភសេពសន្ថវៈ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ដើម្បីជាផលប្រយោជន៍ច្បាប់ ផលប្រយោជន៍ជនរងគ្រោះ និងយុត្តិធម៌ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសំរេច៖

-សម្រេចកែប្រែឈ្មោះបទល្មើសជាបទរំលោភសេពសន្ថវៈ និងពិចារណាសម្រេចតាមក្រមព្រហ្មទណ្ឌវិញ។

-បានស្តាប់ក្រឡាបញ្ជីអានសេចក្តីសង្ខេបរឿងក្តី និងសារណាក្នុងបណ្តឹងសាទុក្ខចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោ[redacted]មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]នាពេលសវនាការថា៖ កូនក្តីខ្ញុំ [redacted]ងកូនស្រីខ្លួនបានយកជាមួយគ្នា គឺមានការត្រូវរ៉ូវគ្នា ដូច្នេះការត្រូវរ៉ូ គឺដោយមានការព្រមព្រៀងជាមួយគ្នាផងដែល។

ចំពោះការប្តូរទីតាំង គឺការសុំឱ្យគេដឹង ព្រោះខ្មាស់គេ ដោយមានគ្នាច្រើន។

ដូច្នេះកូនក្តីខ្ញុំគាត់មិនបានកៀបសង្កត់ទេ ដោយគ្រាន់តែរស់នៅមួយតែប៉ុណ្ណោះ។ បច្ចុប្បន្នកូនក្តីខ្ញុំគាត់ជាប់ពន្ធនាគារបាន១ឆ្នាំមកហើយ។

<u>សំណូមពរ:</u> សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចលើកលែងចោទ ពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ចំពោះរឿងនេះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាម្ចាស់បណ្តឹងសាទុក្ខ ប្តូរបទចោទ ដូចនេះសូមក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ ពិចារណាតាមច្បាប់។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណា នៃបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១៨ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ បានសម្រេចបដិសេធសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តក្រចេះ ហើយប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសជនជាប់ចោ[redacted]ងការប្រព្រឹត្តអំពើល្មើសច្បាប់ព្រហ្មទណ្ឌនោះ ជាការត្រឹមត្រូវហើយ ប៉ុន្តែការដែលយកចិត្តទុកដាក់តែទៅលើអំពើល្មើសច្បាប់ចុងក្រោយ ហើយចោទប្រកាន់ទៅលើជនជាប់ចោទនេះ ពីបទៈ ប៉ុនប៉ុងរំលោភ



Scanned by CamScanner

សេពសន្ថវៈនោះ ពុំទាន់បានស៊ើបសួរឲ្យបានច្បាស់លាស់គ្រប់គ្រាន់ ដើម្បីអាចកំណត់បទល្មើសបាន នៅឡើយទេ ព្រោះថាសំអាងហេតុនៃសាលដីកា បានទទួលស្គាល់រួចហើយថា ជនជាប់ចោទពិតជាបានរំលោភបំពានផ្លូវភេទ ជាមួយក្មួនចុងខ្លួនឯង ជាច្រើនលើកច្រើនសារ។ ដូច្នេះអំពើ ដែលបានប្រព្រឹត្ត ដោយជនជាប់ចោទ ជាច្រើនលើកច្រើនសារកន្លងមកនេះ មិនមែនជាអំពើស្របច្បាប់ទេ សុទ្ធតែជាអំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ មិនគប្បីទុកចោលឲ្យបទល្មើសព្រហ្មទណ្ឌដែលបានកើតឡើងហើយ ស្ថិតនៅក្រៅអានុភាពច្បាប់នោះទេ ដរាបណាមិនទាន់ផុតអាជ្ញាយុកាលនៅឡើយ។ ដោយហេតុថាជាសញ្ញានៃបទល្មើសព្រហ្មទណ្ឌបានកើតឡើង ចាំបាច់ត្រូវស៊ើបសួរបន្ថែមទៀត ដើម្បីពិនិត្យផ្ទៀងផ្ទាត់:

១-ពេលវេលាកើតហេតុ រំលោភបំពានផ្លូវភេទ លើកដំបូងនៅពេលណា ? ពេលនោះកំពុងស្ថិតនៅក្រោមអានុភាពច្បាប់ព្រហ្មទណ្ឌ ណាមួយដែលនៅជាធរមាន ហើយអំពើបន្តបន្ទាប់មកទៀត ស្ថិតនៅក្រោមអានុភាពច្បាប់ព្រហ្មទណ្ឌណាទៀត។ ក្រមព្រហ្មទណ្ឌ ពុំមានអានុភាពប្រតិសកម្មទេ។

២-លក្ខខ័ណ្ឌអនីតិភាពរបស់ជនរងគ្រោះ នៅពេលវេលាកើតហេតុបទល្មើសដំបូង។ ការទទួលខុសត្រូវព្រហ្មទណ្ឌ មានការប្រែប្រួលទៅតាមអាយុរបស់ជនរងគ្រោះ។

-យល់ឃើញថា សារណាក្នុងបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ បានប្តឹងសុំបដិសេធសាលដីកាព្រហ្មទណ្ឌលេខ១៥ក្រIII"ច" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ប៉ុន្តែតាមបណ្តឹងសាទុក្ខលេខ១១៨ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ បានបញ្ជាក់ថា ប្តឹងតវ៉ាតែត្រង់ចំណុចទី៣ នៃសេចក្តីសម្រេចប៉ុណ្ណោះ។ ផ្អែកតាមសេចក្តីសុំប្តឹងសាទុក្ខ មានន័យថា បណ្តឹងសាទុក្ខនេះ បានសុំបដិសេធចោលជាអសារបង់ ត្រង់សេចក្តីសម្រេចចំណុចទី៣ នៃសាលដីកា មិនមែនសុំបដិសេធចោលដីកាទាំងមូលនេះទេ។ ដូច្នេះតុលាការកំពូលមិនពិចារណាលើសេចក្តីសម្រេចផ្សេងទៀត ក្រៅពីចំណុចទី៣ នៃសាលដីកា ដែលមិនមានការប្តឹងតវ៉ានោះឡើយ។

-យល់ឃើញថា ការស៊ើបសួរអាចមានបទល្មើស ដែលត្រូវផ្តន្ទាទោសផ្សេងពីបទល្មើសនៅក្នុងសេចក្តីសម្រេចនោះ គប្បីតុលាការកំពូលអនុវត្តតាមវាក្យខ័ណ្ឌចុងក្រោយ នៃមាត្រា៤៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៥ក្រIII"ច" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវខ្លះ និងមិនត្រឹមត្រូវខ្លះ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ១១៨ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវ។



Scanned by CamScanner

២-បដិសេធចោលជាអសារបង់ គ្រង់សេចក្តីសម្រេចចំណុចទី៣ នៃសាលដីកាព្រហ្មទណ្ឌលេខ១៥ក្រIII"ច" ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២០១ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍វិញ ដើម្បីជំនុំជម្រះជាថ្មី គ្រង់សេចក្តីសម្រេចចំណុចទី៣ នៃសាលដីកានេះ។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
| --- | --- | --- | --- | --- | --- |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី20 ខែ[illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី25 ខែ[illegible] ឆ្នាំ២០១៤

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]



Scanned by CamScanner